ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ១០ រោច ខែ ទុតិយាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន
## វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
## កិច្ចប្រជុំក្រុមការងារ“ក្រុម ឃ”- ផ្នែកនីតិកម្ម ពន្ធដារ និង អភិបាលកិច្ច
## ដើម្បីបន្តពិនិត្យដោះស្រាយបញ្ហារបស់វិស័យឯកជន ដែលកំពុងប្រឈមក្នុងដំណាក់កាល នៃការឆ្លងរាលដាលនៃជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរបង្កដោយវីរុសកូវីដ-១៩

នៅព្រឹកថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០២១, តាមរយៈប្រព័ន្ធវីដេអូ (Video Conference), ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសហប្រធានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច “**ក្រុម ឃ**” នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន រួមជាមួយនឹងលោក **អានូដ ដាក** (Arnaud Darc) សហប្រធាន “**ក្រុម ឃ**” (ខាងផ្នែកឯកជន) ដឹកនាំកិច្ចប្រជុំ “**ក្រុម ឃ**” ក្នុងគោលបំណងបន្តពិនិត្យដោះស្រាយបញ្ហាដែលវិស័យឯកជនកំពុងប្រឈម និងជួបប្រទះ ក្នុងដំណាក់កាលនៃការឆ្លងរីករាលដាលនៃជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរបង្កដោយវីរុសកូវីដ-១៩ ។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីសហសេវិកទាំងផ្នែករាជរដ្ឋាភិបាល វិស័យឯកជន និងតំណាងសភាពាណិជ្ជកម្មកម្ពុជាផងដែរ ។

ជាកិច្ចចាប់ផ្តើម, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានចូលរួមមរណទុក្ខជូនចំពោះ ឯកឧត្តម Bretton G. Sciaroni អតីតសហប្រធានក្រុមការងារដែលបានមរណៈកាលពីពេលថ្មីៗនេះ ។ ឯកឧត្តម Bretton G. Sciaroni បានរួមចំណែកយ៉ាងច្រើនជាមួយរាជរដ្ឋាភិបាល និងបានបន្សល់ទុកនូវសមិទ្ធផលយ៉ាងច្រើន ក្នុងការចូលរួមកសាងនូវបរិយាកាសធុរកិច្ច ការវិនិយោគនៅកម្ពុជា ល្អប្រសើរ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានសំដែងនូវការអបអរសាទរ និងស្វាគមន៍លោក **អានូដ ដាក** ដែលទើបត្រូវបានរាជរដ្ឋាភិបាលទទួលស្គាល់ជាផ្លូវការ តាមសំណើរបស់សភាពាណិជ្ជកម្មកម្ពុជា ជា សហប្រធានក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច “**ក្រុម ឃ**” ផ្នែកឯកជន នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ។

កង្វល់អាទិភាពរបស់វិស័យឯកជនដែលកំពុងប្រឈមក្នុងពេលបច្ចុប្បន្ននេះ ត្រូវបានអង្គប្រជុំធ្វើការពិភាក្សាគឺ ***ការតម្រូវឱ្យធ្វើចត្តាឡីស័ក សម្រាប់និវាសនជន ម្ចាស់អាជីវកម្ម និយោជិក និងវិនិយោគិន*** ដែលធ្វើដំណើរចូលមកកម្ពុជា ក្នុងដំណាក់កាលនៃការឆ្លងរាលដាលនៃជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរបង្កដោយវីរុសកូវីដ-១៩ នេះ ។ កង្វល់នេះ ត្រូវបានពិភាក្សារកដំណោះស្រាយម្តងរួចហើយ នៅក្នុងកិច្ចប្រជុំរវាងវិស័យឯកជន និងអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក ។

ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់វិស័យឯកជន រក្សាបាននូវសកម្មភាពធុរៈកិច្ច ជាមួយនឹងការរក្សាបាននូវឧត្តមប្រយោជន៍ សុវត្ថិភាព សុខភាពរបស់ប្រជាពលរដ្ឋក្នុងកាលៈទេសៈដ៏លំបាកនៃការរីករាតត្បាតនៃជំងឺកូវីដ-១៩, អង្គប្រជុំ បានពិភាក្សាលើបញ្ហាដែលបានលើកឡើងដោយវិស័យឯកជន, បទអន្តរាគមន៍របស់មន្ត្រីជំនាញផ្នែកសុខាភិបាល, អនុគណៈកម្មការគ្រប់គ្រងច្រកចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក រួមទាំង តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗ ។ ជាមួយនឹង *"ការរៀនរស់នៅតាមគន្លងថ្មី (New Normal)"*, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានស្នើ និងជំរុញឱ្យភាគីពាក់ព័ន្ធទាំងអស់ នៃផ្នែករាជរដ្ឋាភិបាល, អនុគណៈកម្មការគ្រប់គ្រងច្រកចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក បន្តខិតខំបន្ថែមទៀត សហការឱ្យកាន់តែជិតស្និទ្ធជាមួយផ្នែកឯកជន យកចិត្តទុកដាក់ តាមដានរាល់បញ្ហារបស់ផ្នែកឯកជនឱ្យជាប់ជាប្រចាំ និងដោះស្រាយទៅតាមករណីជាក់ស្តែង ពិសេស ពាក់ព័ន្ធរយៈពេលនៃការធ្វើចត្តាឡីស័ក, ការកំណត់សណ្ឋាគារសម្រាប់ស្នាក់នៅកំឡុងពេលធ្វើចត្តាឡីស័ក ជាដើម ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកវិនិយោគិន ប៉ុន្តែជាមួយគ្នានេះនៅតែអាចរក្សាឱ្យបានការទប់ស្កាត់ការនាំជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍ ។ កិច្ចការទាំងនេះ គឺជាអាទិភាព រួមចំណែកធានាបានបរិយាកាសល្អប្រសើរសម្រាប់វិស័យឯកជន សម្រាប់ការស្តារសេដ្ឋកិច្ចជាតិឡើងវិញក្រោយ វិបត្តិកូវីដ-១៩ ។

ជាទីបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានវាយតម្លៃខ្ពស់ចំពោះសភាពាណិជ្ជកម្មកម្ពុជា ក្នុងតួនាទីជាអ្នកសម្របសម្រួលការងារខាងផ្នែកឯកជន ពិសេស **"ក្រុម ឃ"** នៃវេទិការាជរដ្ឋាភិបាល-វិស័យឯកជន និងបានលើកទឹកចិត្តដល់សភាពាណិជ្ជកម្មកម្ពុជាឱ្យបន្តនូវតួនាទីជាអ្នកសម្របសម្រួលក្រុមការងារខាងផ្នែកវិស័យឯកជន សំដៅធ្វើឱ្យវិស័យឯកជនកាន់តែមានជីវភាព, ភាពជាម្ចាស់ និងជាដៃគូរឹងមាំរបស់រាជរដ្ឋាភិបាល រួមចំណែកស្តារសេដ្ឋកិច្ចជាតិឡើងវិញក្រោយវិបត្តិកូវីដ-១៩, ជំរុញពិពិធកម្ម និងកំណើនសេដ្ឋកិច្ចជាតិកម្ពុជា ។